**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ ០៩៣/០០៧/២០០២

ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២

**សេចក្តីសំរេច**

លេខ ០៤៧/០០២/២០០២ កបធ.ច

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្តីសំរេចលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការបកស្រាយមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ "
- បានឃើញលិខិតលេខ ៨៣០ រស ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញ-ភាពនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋ-សភាបានអនុម័តយល់ព្រមនៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាលទី ២
- បានឃើញលិខិតលេខ ៦៨៩/០៩០២/អ.ពស/ន.រ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០២ របស់អគ្គលេខាធិការព្រឹទ្ធសភា

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ ។

- យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ ។
- យល់ឃើញថា ប្រធានព្រឹទ្ធសភា ( ស្តីទី ) ដែលបានសរសេរថា ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យអត្ថបទច្បាប់នេះ ពុំបានបើកសម័យប្រជុំព្រឹទ្ធសភាពេញអង្គដើម្បីអនុម័តសេចក្តីសំរេចយ៉ាងដូចនេះទេ ។ ដូច្នេះ គឺជាសេចក្តីសំរេចឯកតោភាគីផ្ទាល់ខ្លួនរបស់ប្រធានព្រឹទ្ធសភា ( ស្តីទី ) គឺថាមិនមែនរបស់ព្រឹទ្ធសភាដូចដែលមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានតម្រូវនោះឡើយ ។
- យល់ឃើញថា ក្នុងករណីដូចបានលើកឡើងខាងលើនេះ វិធានទាំងឡាយដែលមានចែងក្នុងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការបកស្រាយមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ក៏មិនត្រូវបានអនុវត្តតាមដែរ ។
- យល់ឃើញថា ការគោរពនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ជាការចាំបាច់សំរាប់តម្រូវការនៃនីត្យានុកូលភាព ដែលចាប់ពីពេលនេះតទៅមិនគួរឱ្យមានការខ្វះខាតទៀតឡើយ ។
- យល់ឃើញថា ទំរង់នៃការតាក់តែង និងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។
- យល់ឃើញថា ខ្លឹមសារមាត្រាទាំងពីរនៃច្បាប់នេះក៏ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

**សំរេច**

**មាត្រា ១ :** យោងតាមមូលបទខាងលើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ :** សេចក្តីសំរេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអនុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន